# សម្បត្តិខ្មែរ ខ្មែរថៃ

ក កាយកើតមកឈាមជាខ្មែរ
ខ ខំជួយថែភាសាជាតិ
គ គិតសិក្សាកុំបីឃ្លាត
ឃ ឃាត់មារយាទដៀលជាតិខ្លួន។
ង ងើបមុខឡើងកុំឆ្មើងឆ្មៃ
ច ចាប់កែថ្មៃឫកសមសួន
ឆ ឆាប់ចាប់ចិត្តកុំគេចពួន
ជ ជួយថែក្បួនច្បាប់ខេមរា ។
ឈ ឈានទៅមុខកុំភ្លេចក្រោយ
ញ ញាតិខ្សត់ខ្សោយគួរក្សា
ដ ដក់ជាប់រាប់ក្នុងចិន្តា
ឋ ឋិតឋានណាចេះប្រណី។
ឌ ឌឹដងគ្នាគួរខ្មាស់ក្អាត់
ឍ ឍោមរសត្វឫកប្រពៃ
ណ ណាយដំណើរជួរអប្រិយ
ត តាំងនិស្ស័យខ្ពស់ថ្លៃថ្នូរ ។
ថ ថៃកុំឃ្លាតជាតិសាសនា
ទ ទោះឆ្ងាយរ៉ាគិតកុំមោហ៍
ធ ធាងស្លឹកមែកបែកហែហូរ
ន នៅស្ងួយទ្រលំអដើម ។
ប បានសាន្តសុខនៅស្រុកគេ
ផ ផុតទន្លេទុក្ខសំបើម
ព ពិតសំណាងយ៉ាងល្អឆ្នើម
ភ ភ័យគួរខ្ពើមហៅគ្មានពិត ។
ម មើលអោយច្បាស់ចេះខ្មាស់អៀន
យ យកមេរៀនពីអតីត
រ រិះគិតគន់ប្រឹងពិនិត្យ
ល លះកុំជិតរឿងអប្រិយ ។
វ វឹកប្រចឹកប្រឈ្លោះគ្នា
ស សុខរមនាមានដែរអី
ហ ហាក់ស្រោតកាយអួតលោកិយ
ឡ ឡើងដើមជ្រៃចំកោងកាយ ។
អ អាងអំនួតអួតឥតខ្មាស់
ឥតមើលឥតផ្លាស់ឫកពីអាយ
ជាតិគេគេថៃគ្មានរសាយ
យើងគួរគន់ឆ្ងាយមើលគេផង ។

អូត្តាវ៉ា ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥